**សកម្មភាព** ៖ **ល្បែងកាយវិការការងារ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)

**ភាសាខ្មែរ**

ការស្ដាប់ (ស្ដាប់គេនិយាយ និងមានសម្ថភាពស្ដាប់ដោយធ្វើតាមការណែនាំងាយៗ)

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ។
ប្រាប់ពីការរត់ ដើរ លោត ឬ លើសពីនេះទៅតាមទម្រង់នៃសកម្មភាពផ្សេងៗ។

**(ភាសាខ្មែរ)** ប្រាប់បានខ្លះពីដំណើររឿង តាមរយៈរូបភាពដែលបានបង្ហាញ ឬ សួរសំណួរ។
ប្រាប់ពីសកម្មភាពតាមដំណាក់កាលដោយអនុវត្តតាមការណែនាំ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ១០ នាទី

**ឧបករណ៍** ៖ គ្មាន

**ការរៀបចំ** ៖ បង្កើតសាច់រឿងខ្លីៗដែលទាក់ទងតែការងារប៉ុណ្ណោះ ហើយផ្សេងៗគ្នានឹងធ្វើសកម្មភាពបណ្ដើរផងដែរ ។

**សេចក្តីណែនាំ៖**

1. ពន្យល់ក្មេងៗថាអ្នកនឹងនិយាយពីសាច់រឿងមួយឱ្យពួកគេស្ដាប់ ហើយធ្វើកាយវិការឱ្យមើល រួចឱ្យក្មេងៗធ្វើកាយវិការតាម។
2. ដំបូងធ្វើឱ្យក្មេងៗមើលដោយយឺតៗ ដើម្បីឱ្យក្មេងៗទាំងអស់បានមើលបានយ៉ាងច្បាស់ និងបន្ទាប់មកឱ្យពួកគេធ្វើកាយវិការតាម។

**ឧទាហរណ៍សាច់រឿង (ឧ. អ្នកពន្លត់អគ្គីភ័យ)**

1. ថ្ងៃមួយអ្នកពន្លត់អគ្គីភ័យ កំពុងដេក។ **(ធ្វើដូចជាកំពុងដេក)**

2. ភ្លាមៗនោះ គាត់បានលឺសម្លេងប្រកាសអាសន្នមួយ។ (មានម៉ោងរោរ៍សម្រាប់ធ្វើការដាសតឿន) **(លោត និងមើលទៅហាក់បីដូចជា ភ្ញាក់ផ្អើល)**
3. គាត់បានស្លៀកពាក់យ៉ាងលឿន។ **(សម្លៀកបំពាក់អ្នកពន្លត់អគ្គីភ័យ)**
4. គាត់រត់កន្លែងចតឡានអគ្គីភ័យ។ **(ធ្វើដូចជារត់ទៅកន្លែងហ្នឹង)**
5. គាត់បានបើកឡានអគ្គីភ័យ។ **(ដៃលាតសន្ធឹងកាន់ចង្កូត ហើយធ្វើចលនាជាកន្លះរង្វង់)**
6. គាត់ចាប់ផ្តើមលេងបាញ់ទឹក។ **(កាន់ទុយោធូន់ ហើយរំកិលវាចេញ)**
7. អូទេ! គាត់ឃើញឆ្មាមួយ។ **(មើលទៅឡើរឱ្យរន្ទត់)**
8. គាត់ឡើងជណ្តើរ។ **(ចលនាឡើងលើ)**
9. ចាប់ឆ្មាហើយឡើងចុះម្តងទៀត។ **(ឡើងចុះចលនា)**
10. ភូ! ទាន់ពេល។ **(ជូតចង្វាសរបស់អ្នកដោយប្រើកំភួនដៃខាងក្រោយ)**

3. ប្រាប់សាច់រឿងម្តងទៀតដោយលឿងជាងមុន និងដោយមានភាពទាក់ទាញជាមុន។
4. បន្តការប្រាប់រឿងនោះទៀត ប្រាប់រឿងថ្មី ឬ ឱ្យក្មេងៗបង្កើតសាច់រឿងផ្សេងទៀតបាន។
5. បង្កើតជាសាច់រឿងផ្សេងទៀតដែលដូចជា៖ អ្នករាំ អ្នកធ្វើការសំណង់ និងការងារផ្សេងៗទៀត។